# របាយការណ៍ស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាលថ្នាក់ជាតិ

# ប្រចាំខែកញ្ញា ឆ្នាំ ២០១៩

*(ទិន្នន័យបឋម)*

**មាតិកា** **ទំព័រ**


១.សេចក្តីសង្ខេប ១

២.តារាងស្ថិតិ

២.១.តារាងសង្ខេបប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋាភិបាល ២

២.២.តារាងស្ថិតិចំណូល ៣

២.៣.តារាងស្ថិតិចំណាយ ៥

២.៤.តារាងស្ថិតិបម្រែបម្រួលទ្រព្យសកម្ម/បំណុល ៦

៣.ក្រាហ្វិក ៧

៤.ឧបសម្ព័ន្ធស្ថិតិហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ ៩

៥.តារាងស្ថិតិពីភាពខុសគ្នានៃស្ថិតិ TOFE និងស្ថិត GFS ១០

៦.សេចក្តីសង្ខេបអំពី "ក្របខ័ណ្ឌប្រព័ន្ធស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល" ១៣


Reference: Government Finance Statistics Manual 2014 (GFSM 2014)

## ១.សេចក្តីសង្ខេប
## ស្តីពីការអនុវត្តថវិកា ខែកញ្ញា ឆ្នាំ ២០១៩

(១).**ការអនុវត្តចំណូល÷** ក្នុងខែកញ្ញា ឆ្នាំ២០១៩នេះ ចំណូលរដ្ឋបាលថ្នាក់ជាតិអនុវត្តបាន **២ ១៤៩ ៥២៨** លានរៀលគឺបានកើនឡើង **៣០,៩៩%** ឬស្មើនឹង **៥០៣ ៥៧៣** លានរៀល បើធៀបនឹងខែកញ្ញា ឆ្នាំ២០១៨។ គិតត្រឹមរយៈពេល ៩ខែ នៃឆ្នាំ២០១៩ ចំណូលរដ្ឋបាលថ្នាក់ជាតិសរុបអនុវត្តបាន **១៨ ៣៤៧ ៨៩៩** លានរៀល ឬស្មើនឹង **៩១,៨៦%** នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៩ ឬបានកើនឡើង **១៩,៤១%** បើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៨។ ចំណូលនេះត្រូវបានគាំទ្រដោយចំណូលពន្ធប្រមាណ **៨៣,៨៦%** ចំណូលផ្សេងៗ **១១,៦៣%** និងចំណូលពីអំណោយប្រមាណ **៤,៥១%**។

(២).**ចំណាយសរុប÷** ក្នុងខែកញ្ញាឆ្នាំ២០១៩នេះ ចំណាយសរុបរដ្ឋបាលថ្នាក់ជាតិអនុវត្តបាន **១ ៥៤១ ៩៦៩** លានរៀលគឺបានថយចុះ **១៦,៦២%** ឬស្មើនឹង **៣០៣ ៤៦៤** លានរៀល បើធៀបទៅនឹងខែកញ្ញា ឆ្នាំ២០១៨ ដែលក្នុងនោះចំណាយអនុវត្តបាន **១ ២៨៦ ៥៤៩** លានរៀល និងទ្រព្យមិនមែនហិរញ្ញវត្ថុអនុវត្តបាន **២៥៥ ៤២០** លានរៀល។ គិតត្រឹមរយៈពេល ៩ខែ នៃឆ្នាំ២០១៩នេះ ចំណាយសរុបអនុវត្តបាន **១៤ ៣៥៧ ៧៦៦** លានរៀល ឬស្មើនឹង **៦១,៥៧%** នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៩ ឬបានកើនឡើង **១,០៨%** បើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៨។ ក្នុងចំណាយសរុបនេះរួមមាន**ចំណាយ** (expense) សម្រេចបាន **៦៤,៤០%** និង**ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ** (net acquisition of non-financial assets) សម្រេចបាន **៥៥,១៧%** នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៩។

(៣).**តុល្យភាពប្រតិបត្តិការដុល** (ចំណូលដកចំណាយ)÷ គិតត្រឹមខែកញ្ញា ឆ្នាំ២០១៩នេះ តុល្យភាពប្រតិបត្តិការដុលមានសមតុល្យចំនួន **៧ ៩៤១ ៦៥៧** លានរៀល ឬបានកើនឡើង **៣៦,៥៥%** បើធៀបទៅនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៨។ ចំណែកឯ **សមតុល្យនៃការឱ្យខ្ចី/ខ្ចីប្រាក់កម្ចីសុទ្ធ** (ចំណូលដកចំណាយសរុប) គិតត្រឹមខែកញ្ញា ឆ្នាំ២០១៩នេះមានសមតុល្យចំនួន **៣ ៩៩០ ១៣៤** លានរៀល ដែលក្នុងនោះមានទ្រព្យសកម្មហិរញ្ញវត្ថុសុទ្ធសរុបចំនួន **៥ ២៩៨ ៩១៥** លានរៀល និងបំណុលសរុបមានចំនួន **១ ៣២២ ៩៨២** លានរៀល។

(៤).**សន្និដ្ឋាន÷** ផ្អែកលើទិន្នន័យបឋមនៃការអនុវត្តរយៈពេល៩ខែ នៃឆ្នាំ២០១៩នេះ ការអនុវត្តថវិការដ្ឋបាលថ្នាក់ជាតិនៅតែទទួលបានលទ្ធផលល្អធៀបនឹងឆ្នាំ២០១៨ បើទោះបីជាកំណើនហាក់ដូចជាមិនសូវមានសន្ទុះក៏ដោយស្របពេលដែលចំណាយសរុបអនុវត្តបានត្រឹមតែ **៦១,៥៧%** នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៩ ដែលត្រូវជំរុញការអនុវត្តបន្ថែមទៀត។

✵✵✵✵✵

# ២.១. ប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋាភិបាល

ឯកតា÷ លានរៀល

| | | ច្បាប់ឆ្នាំ ២០១៩ | អនុវត្តន៍ ២០១៩ | អនុ/ច្ប ២០១៩ | ប្រចាំខែ មករា | ប្រចាំខែ កុម្ភៈ | ប្រចាំខែ មីនា | ប្រចាំខែ មេសា | ប្រចាំខែ ឧសភា | ប្រចាំខែ មិថុនា | ប្រចាំខែ កក្កដា | ប្រចាំខែ សីហា | ប្រចាំខែ កញ្ញា | ប្រចាំខែ តុលា | ប្រចាំខែ វិច្ឆិកា | ប្រចាំខែ ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | វិធីសាស្ត្រគណនេយ្យ | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash |
| **1** | **ចំណូល** | **20,632,855.0** | **18,347,899.3** | **88.93%** | **1,589,764.7** | **1,462,689.0** | **2,241,945.2** | **2,347,189.4** | **2,032,635.5** | **2,157,788.7** | **2,146,296.9** | **2,220,061.6** | **2,149,528.3** | **0.0** | **0.0** | **0.0** |
| 11 | ពន្ធ | 16,626,000.0 | 15,385,833.5 | 92.54% | 1,420,958.5 | 1,240,961.4 | 1,797,607.5 | 2,097,195.1 | 1,781,842.9 | 1,739,335.7 | 1,682,021.1 | 1,808,915.8 | 1,816,995.5 | 0.0 | 0.0 | 0.0 |
| 13 | អំណោយ | 1,189,753.0 | 827,305.2 | 69.54% | 88,729.4 | 88,729.4 | 88,729.4 | 88,729.4 | 88,729.4 | 88,824.2 | 94,742.2 | 93,065.5 | 107,026.3 | 0.0 | 0.0 | 0.0 |
| 14 | ចំណូលផ្សេងៗ | 2,817,102.0 | 2,134,760.6 | 75.78% | 80,076.8 | 132,998.2 | 355,608.3 | 161,264.9 | 162,063.2 | 329,628.8 | 369,533.6 | 318,080.3 | 225,506.6 | 0.0 | 0.0 | 0.0 |
| **2** | **ចំណាយ** | **15,404,610.8** | **10,406,241.9** | **67.55%** | **955,189.3** | **788,229.4** | **1,250,075.1** | **981,224.6** | **1,194,805.7** | **1,338,842.1** | **1,364,076.6** | **1,247,249.9** | **1,286,549.0** | **0.0** | **0.0** | **0.0** |
| 21 | បន្ទុកបុគ្គលិក | 7,731,219.9 | 5,663,266.6 | 73.25% | 567,032.3 | 545,595.4 | 684,204.5 | 542,299.6 | 613,089.5 | 692,869.6 | 712,086.8 | 654,314.4 | 651,774.3 | 0.0 | 0.0 | 0.0 |
| 22 | ទំនិញ និងសេវាកម្ម | 3,156,676.8 | 1,353,177.5 | 42.87% | 31,086.1 | 76,603.5 | 84,867.3 | 123,585.7 | 188,249.0 | 163,603.0 | 227,878.3 | 261,863.9 | 195,440.6 | 0.0 | 0.0 | 0.0 |
| 24 | ការប្រាក់ | 525,089.0 | 327,057.5 | 62.29% | 62,608.2 | 50,120.9 | 38,398.7 | 9,578.1 | 7,152.3 | 1,825.1 | 69,094.4 | 65,961.8 | 22,318.0 | 0.0 | 0.0 | 0.0 |
| 25 | ឧបត្ថម្ភកធន | 11,000.0 | … | … | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| 26 | អំណោយ | 1,296,571.8 | 1,158,605.0 | 89.36% | 206,840.8 | 7,515.2 | 136,246.2 | 210,623.3 | 93,397.7 | 187,391.8 | 239,283.7 | 36,167.8 | 41,138.5 | 0.0 | 0.0 | 0.0 |
| 27 | ឧបត្ថម្ភសង្គមកិច្ច | 1,596,371.5 | 1,212,335.4 | 75.94% | 82,249.1 | 77,026.3 | 166,507.3 | 54,579.0 | 244,548.2 | 175,178.8 | 34,452.1 | 186,513.8 | 191,281.0 | 0.0 | 0.0 | 0.0 |
| 28 | ចំណាយផ្សេងៗ | 1,087,681.8 | 691,799.9 | 63.60% | 5,372.8 | 31,368.1 | 139,851.2 | 40,558.8 | 48,369.0 | 117,973.8 | 81,281.4 | 42,428.1 | 184,596.6 | 0.0 | 0.0 | 0.0 |
| ***GOB*** | ***តុល្យភាពប្រតិបត្តិការដុល*** | **5,228,244.2** | **7,941,657.4** | **151.90%** | **634,575.4** | **674,459.6** | **991,870.0** | **1,365,964.8** | **837,829.8** | **818,946.6** | **782,220.2** | **972,811.7** | **862,979.3** | **0.0** | **0.0** | **0.0** |
| ***NOB*** | ***តុល្យភាពប្រតិបត្តិការសុទ្ធ*** | **5,228,244.2** | **7,941,657.4** | **151.90%** | **634,575.4** | **674,459.6** | **991,870.0** | **1,365,964.8** | **837,829.8** | **818,946.6** | **782,220.2** | **972,811.7** | **862,979.3** | **0.0** | **0.0** | **0.0** |
| **31** | **ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុសុទ្ធ** | 8,384,277.6 | 3,951,523.6 | 47.13% | 268,327.0 | 285,839.1 | 608,778.5 | 441,431.8 | 396,412.6 | 562,088.0 | 696,557.5 | 436,668.9 | 255,420.3 | 0.0 | 0.0 | 0.0 |
| 311 | ទ្រព្យអចលត៍ | 8,384,277.6 | 3,936,229.9 | 46.95% | 268,327.0 | 285,839.1 | 608,778.5 | 436,335.6 | 396,412.6 | 562,088.0 | 696,557.5 | 426,471.4 | 255,420.3 | 0.0 | 0.0 | 0.0 |
| 314 | ទ្រព្យសកម្មគ្មានផលិតភាព | 0.0 | 15,293.7 | … | 0.0 | 0.0 | 0.0 | 5,096.2 | 0.0 | 0.0 | 0.0 | 10,197.5 | 0.0 | 0.0 | 0.0 | 0.0 |
| ***2M*** | ***ចំណាយសរុប*** | 23,788,888.4 | 14,357,765.5 | 60.35% | 1,223,516.3 | 1,074,068.5 | 1,858,853.6 | 1,422,656.3 | 1,591,218.3 | 1,900,930.2 | 2,060,634.1 | 1,683,918.8 | 1,541,969.3 | 0.0 | 0.0 | 0.0 |
| ***NLB*** | ***សមតុល្យនៃការអោយខ្ចី/ប្រាក់កម្ចី*** | **-3,156,033.4** | **3,990,133.8** | **…** | **366,248.4** | **388,620.5** | **383,091.6** | **924,533.1** | **441,417.3** | **256,858.6** | **85,662.7** | **536,142.8** | **607,559.0** | **0.0** | **0.0** | **0.0** |
| **32** | **ទ្រព្យហិរញ្ញវត្ថុសុទ្ធ** | -193,149.0 | 5,298,915.0 | … | 517,480.6 | 385,388.0 | 621,555.7 | 1,099,412.6 | 576,976.6 | 560,340.8 | 410,163.1 | 527,938.2 | 599,659.3 | 0.0 | 0.0 | 0.0 |
| 321 | ក្នុងប្រទេស | -193,149.0 | 5,298,915.0 | … | 517,480.6 | 385,388.0 | 621,555.7 | 1,099,412.6 | 576,976.6 | 560,340.8 | 410,163.1 | 527,938.2 | 599,659.3 | 0.0 | 0.0 | 0.0 |
| **33** | **បំណុលសុទ្ធ** | 3,478,067.0 | 1,322,981.5 | 38.04% | 151,385.4 | -3,185.7 | 238,393.8 | 174,673.2 | 146,438.7 | 303,458.6 | 327,974.9 | -8,216.8 | -7,940.5 | 0.0 | 0.0 | 0.0 |
| 332 | ក្រៅប្រទេស | 3,478,067.0 | 1,322,981.5 | 38.04% | 151,385.4 | -3,185.7 | 238,393.8 | 174,673.2 | 146,438.7 | 303,458.6 | 327,974.9 | -8,216.8 | -7,940.5 | 0.0 | 0.0 | 0.0 |

ថ្ងៃ ខែ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៩
**អគ្គនាយក**
**អគ្គនាយកដ្ឋានគោលនយោបាយ**

ថ្ងៃ ខែ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៩
**ប្រធាននាយកដ្ឋាន**
**នាយកដ្ឋានស្ថិតិ និងវិភាគសេដ្ឋកិច្ច**

ថ្ងៃ ខែ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៩
**ប្រធានការិយាល័យ**
**ការិយាល័យស្ថិតិហិរញ្ញវត្ថុសាធារណៈ**

# ២.២.តារាងស្ថិតិចំណូល

ឯកតា÷ លានរៀល

| | | ច្បាប់ឆ្នាំ ២០១៩ | អនុវត្តន៍ ២០១៩ | អនុ/ច្ប ២០១៩ | ប្រចាំខែ មករា | ប្រចាំខែ កុម្ភៈ | ប្រចាំខែ មីនា | ប្រចាំខែ មេសា | ប្រចាំខែ ឧសភា | ប្រចាំខែ មិថុនា | ប្រចាំខែ កក្កដា | ប្រចាំខែ សីហា | ប្រចាំខែ កញ្ញា | ប្រចាំខែ តុលា | ប្រចាំខែ វិច្ឆិកា | ប្រចាំខែ ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | វិធីសាស្ត្រគណនេយ្យ | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash |
| **1** | **ចំណូល** | **20,632,855.0** | **18,347,899.3** | **88.93%** | **1,589,764.7** | **1,462,689.0** | **2,241,945.2** | **2,347,189.4** | **2,032,635.5** | **2,157,788.7** | **2,146,296.9** | **2,220,061.6** | **2,149,528.3** | **0.0** | **0.0** | **0.0** |
| **11** | **ពន្ធ** | **16,626,000.0** | **15,385,833.5** | **92.54%** | **1,420,958.5** | **1,240,961.4** | **1,797,607.5** | **2,097,195.1** | **1,781,842.9** | **1,739,335.7** | **1,682,021.1** | **1,808,915.8** | **1,816,995.5** | **0.0** | **0.0** | **0.0** |
| **111** | **ពន្ធលើប្រាក់ចំណូល និងប្រាក់ចំណេញ** | 4,330,000.0 | 3,516,751.7 | 81.22% | 250,812.8 | 210,614.6 | 541,930.7 | 816,803.0 | 486,811.8 | 308,522.7 | 302,757.9 | 300,915.9 | 297,582.3 | 0.0 | 0.0 | 0.0 |
| 1111 | ពន្ធរូបវន្តបុគ្គល | 1,080,000.0 | 646,962.4 | 59.90% | 72,224.1 | 67,427.8 | 79,679.2 | 73,609.7 | 67,638.5 | 83,733.7 | 73,617.3 | 56,576.4 | 72,455.8 | 0.0 | 0.0 | 0.0 |
| 1112 | ពន្ធនីតិបុគ្គល | 3,250,000.0 | 2,869,789.3 | 88.30% | 178,588.7 | 143,186.8 | 462,251.4 | 743,193.4 | 419,173.3 | 224,789.0 | 229,140.7 | 244,339.5 | 225,126.5 | 0.0 | 0.0 | 0.0 |
| **114** | **ពន្ធលើទំនិញ និងសេវាប្រើប្រាស់** | 9,888,500.0 | 9,749,370.5 | 98.59% | 943,689.0 | 847,244.8 | 1,046,090.1 | 1,026,763.1 | 1,061,846.5 | 1,190,847.9 | 1,123,961.1 | 1,231,284.2 | 1,277,643.8 | 0.0 | 0.0 | 0.0 |
| 1141 | ពន្ធទូទៅលើទំនិញ និងសេវាប្រើប្រាស់ | 5,751,500.0 | 5,076,331.2 | 88.26% | 493,207.1 | 423,814.1 | 582,182.4 | 514,494.5 | 511,027.5 | 636,335.3 | 571,475.6 | 631,441.1 | 712,353.8 | 0.0 | 0.0 | 0.0 |
| 11411 | អាករលើតម្លៃបន្ថែម | 5,751,500.0 | 5,076,315.3 | 88.26% | 493,207.0 | 423,814.1 | 582,182.2 | 514,494.3 | 511,012.9 | 636,335.3 | 571,474.6 | 631,441.1 | 712,353.8 | 0.0 | 0.0 | 0.0 |
| 11413 | ពន្ធលើផលរបរ និងពន្ធលើទំនិញ និងសេវាកម្មផ្សេងៗ | 0.0 | 15.9 | … | 0.0 | 0.0 | 0.1 | 0.1 | 14.6 | 0.0 | 1.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| 1142 | អាករពិសេស | 4,137,000.0 | 4,673,039.3 | 112.96% | 450,481.9 | 423,430.7 | 463,907.7 | 512,268.6 | 550,819.0 | 554,512.6 | 552,485.6 | 599,843.2 | 565,290.0 | 0.0 | 0.0 | 0.0 |
| **115** | **ពន្ធលើពាណិជ្ជកម្មអន្តរជាតិ** | 2,398,000.0 | 2,105,147.6 | 87.79% | 226,331.3 | 182,735.1 | 207,317.4 | 242,745.5 | 232,534.4 | 239,893.4 | 255,195.0 | 276,643.0 | 241,752.5 | 0.0 | 0.0 | 0.0 |
| 1151 | អាករ និងបន្ទុកនាំចូលផ្សេងៗ | 2,348,500.0 | 2,069,013.0 | 88.10% | 221,879.2 | 179,972.4 | 202,917.9 | 238,734.8 | 226,993.0 | 236,459.2 | 251,441.7 | 272,251.7 | 238,363.1 | 0.0 | 0.0 | 0.0 |
| 1152 | ពន្ធនាំចេញ | 49,500.0 | 36,134.6 | 73.00% | 4,452.1 | 2,762.7 | 4,399.5 | 4,010.7 | 5,541.4 | 3,434.2 | 3,753.4 | 4,391.3 | 3,389.4 | 0.0 | 0.0 | 0.0 |
| **116** | **ពន្ធផ្សេង ៗ** | 9,500.0 | 14,563.8 | 153.30% | 125.4 | 366.9 | 2,269.3 | 10,883.5 | 650.2 | 71.8 | 107.1 | 72.7 | 16.9 | 0.0 | 0.0 | 0.0 |
| **13** | **អំណោយ** | **1,189,753.0** | **827,305.2** | **69.54%** | **88,729.4** | **88,729.4** | **88,729.4** | **88,729.4** | **88,729.4** | **88,824.2** | **94,742.2** | **93,065.5** | **107,026.3** | **0.0** | **0.0** | **0.0** |
| **131** | **អំណោយពីរដ្ឋាភិបាលអន្តរជាតិ** | 319,426.0 | 268,215.2 | 83.97% | 26,618.8 | 26,618.8 | 26,618.8 | 26,618.8 | 26,618.8 | 26,618.8 | 32,631.6 | 30,954.9 | 44,915.7 | 0.0 | 0.0 | 0.0 |
| 1312 | មូលធន | 319,426.0 | 268,215.2 | 83.97% | 26,618.8 | 26,618.8 | 26,618.8 | 26,618.8 | 26,618.8 | 26,618.8 | 32,631.6 | 30,954.9 | 44,915.7 | 0.0 | 0.0 | 0.0 |
| **132** | **អំណោយពីអង្គការអន្តរជាតិ** | 870,327.0 | 558,995.3 | 64.23% | 62,110.6 | 62,110.6 | 62,110.6 | 62,110.6 | 62,110.6 | 62,110.6 | 62,110.6 | 62,110.6 | 62,110.6 | 0.0 | 0.0 | 0.0 |
| 1322 | មូលធន | 870,327.0 | 558,995.3 | 64.23% | 62,110.6 | 62,110.6 | 62,110.6 | 62,110.6 | 62,110.6 | 62,110.6 | 62,110.6 | 62,110.6 | 62,110.6 | 0.0 | 0.0 | 0.0 |
| **14** | **ចំណូលផ្សេងៗ** | **2,817,102.0** | **2,134,760.6** | **75.78%** | **80,076.8** | **132,998.2** | **355,608.3** | **161,264.9** | **162,063.2** | **329,628.8** | **369,533.6** | **318,080.3** | **225,506.6** | **0.0** | **0.0** | **0.0** |
| **141** | **ចំណូលពីទ្រព្យសម្បត្តិ** | 270,112.4 | 352,007.0 | 130.32% | 3,187.3 | 6,176.6 | 197,956.8 | 13,234.2 | 17,346.0 | 36,457.9 | 19,117.2 | 36,313.5 | 22,217.3 | 0.0 | 0.0 | 0.0 |
| 1411 | ចំណូលការប្រាក់ | 127,379.0 | 103,451.6 | 81.22% | 0.0 | 1,267.1 | 27,067.8 | 2,096.5 | 6,238.8 | 21,377.4 | 6,409.8 | 22,549.1 | 16,445.1 | 0.0 | 0.0 | 0.0 |
| 14112 | ចំណូលការប្រាក់ក្នុងប្រទេស | 127,379.0 | 103,451.6 | 81.22% | 0.0 | 1,267.1 | 27,067.8 | 2,096.5 | 6,238.8 | 21,377.4 | 6,409.8 | 22,549.1 | 16,445.1 | 0.0 | 0.0 | 0.0 |
| 1412 | ចំណូលភាគលាភ | 21,250.0 | 170,718.9 | 803.38% | 0.0 | 0.0 | 165,898.9 | 2,000.0 | 2,500.0 | 320.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| 1413 | ចំណូលផលទុននៃសេវាផ្គត់ផ្គង់ (អគ្គិសនី, ទឹក...) | 36.8 | 50.8 | 138.02% | 0.0 | 0.0 | 17.3 | 0.0 | 0.0 | 18.7 | 0.0 | 14.8 | 0.0 | 0.0 | 0.0 | 0.0 |
| 1415 | ចំណូលពីការជួល | 121,446.6 | 77,785.7 | 64.05% | 3,187.3 | 4,909.6 | 4,972.8 | 9,137.8 | 8,607.2 | 14,741.8 | 12,707.4 | 13,749.6 | 5,772.2 | 0.0 | 0.0 | 0.0 |

# ២.២.តារាងស្ថិតិចំណូល

ឯកតា÷ លានរៀល

| | | ច្បាប់ឆ្នាំ ២០១៩ | អនុវត្តន៍ ២០១៩ | អនុ/ច្ប ២០១៩ | ប្រចាំខែ មករា | ប្រចាំខែ កុម្ភៈ | ប្រចាំខែ មីនា | ប្រចាំខែ មេសា | ប្រចាំខែ ឧសភា | ប្រចាំខែ មិថុនា | ប្រចាំខែ កក្កដា | ប្រចាំខែ សីហា | ប្រចាំខែ កញ្ញា | ប្រចាំខែ តុលា | ប្រចាំខែ វិច្ឆិកា | ប្រចាំខែ ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | វិធីសាស្រ្តគណនេយ្យ | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash |
| **142** | **ចំណូលពីការលក់ទំនិញ និងសេវាកម្ម** | 2,281,014.0 | 1,674,125.6 | 73.39% | 68,724.3 | 119,275.9 | 144,430.8 | 140,603.0 | 137,098.5 | 275,285.2 | 334,168.6 | 262,647.4 | 191,891.8 | 0.0 | 0.0 | 0.0 |
| 1421 | ចំណូលពីការលក់ក្នុងទីផ្សារ | 634,026.6 | 513,414.7 | 80.98% | 8,414.2 | 14,220.0 | 17,598.1 | 42,137.9 | 38,544.7 | 65,838.8 | 181,696.8 | 105,849.5 | 39,114.8 | 0.0 | 0.0 | 0.0 |
| 1422 | ចំណូលសេវារដ្ឋបាល | 1,111,248.8 | 862,612.8 | 77.63% | 15,994.8 | 59,066.8 | 125,343.4 | 26,682.3 | 97,603.0 | 161,310.5 | 130,640.6 | 124,808.8 | 121,162.8 | 0.0 | 0.0 | 0.0 |
| 1423 | ចំណូលពីការលក់ ឬសកម្មភាពផ្សេងៗ(ទេសចរណ៍, វប្បធម៌...) | 535,738.6 | 298,098.0 | 55.64% | 44,315.4 | 45,989.1 | 1,489.3 | 71,782.8 | 950.9 | 48,135.9 | 21,831.2 | 31,989.2 | 31,614.3 | 0.0 | 0.0 | 0.0 |
| **143** | **ចំណូលបានពីការពិន័យ** | 133,774.3 | 107,311.7 | 80.22% | 8,113.5 | 7,484.6 | 13,083.8 | 7,356.8 | 7,499.9 | 17,664.8 | 15,939.6 | 18,940.8 | 11,227.9 | 0.0 | 0.0 | 0.0 |
| **144** | **ការផ្ទេរផ្សេងៗដែលមិនបានញែក** | 132,201.3 | 1,316.3 | 1.00% | 51.6 | 61.1 | 136.9 | 70.9 | 118.7 | 220.8 | 308.2 | 178.7 | 169.5 | 0.0 | 0.0 | 0.0 |
| 1441 | ចរន្ត | 132,201.3 | 1,316.3 | 1.00% | 51.6 | 61.1 | 136.9 | 70.9 | 118.7 | 220.8 | 308.2 | 178.7 | 169.5 | 0.0 | 0.0 | 0.0 |
| 14412 | ផ្សេងៗ | 132,201.3 | 1,316.3 | 1.00% | 51.6 | 61.1 | 136.9 | 70.9 | 118.7 | 220.8 | 308.2 | 178.7 | 169.5 | 0.0 | 0.0 | 0.0 |

# ២.៣.តារាងស្ថិតិចំណាយ

ឯកតា÷ លានរៀល

| | | ច្បាប់ឆ្នាំ ២០១៩ | អនុវត្តន៍ ២០១៩ | អនុ/ច្ប ២០១៩ | ប្រចាំខែ មករា | ប្រចាំខែ កុម្ភៈ | ប្រចាំខែ មីនា | ប្រចាំខែ មេសា | ប្រចាំខែ ឧសភា | ប្រចាំខែ មិថុនា | ប្រចាំខែ កក្កដា | ប្រចាំខែ សីហា | ប្រចាំខែ កញ្ញា | ប្រចាំខែ តុលា | ប្រចាំខែ វិច្ឆិកា | ប្រចាំខែ ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | វិធីសាស្រ្តគណនេយ្យ | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash |
| **2** | **ចំណាយ** | **15,404,610.8** | **10,406,241.9** | **67.55%** | **955,189.3** | **788,229.4** | **1,250,075.1** | **981,224.6** | **1,194,805.7** | **1,338,842.1** | **1,364,076.6** | **1,247,249.9** | **1,286,549.0** | **0.0** | **0.0** | **0.0** |
| **21** | **បន្ទុកបុគ្គលិក** | **7,731,219.9** | **5,663,266.6** | **73.25%** | **567,032.3** | **545,595.4** | **684,204.5** | **542,299.6** | **613,089.5** | **692,869.6** | **712,086.8** | **654,314.4** | **651,774.3** | **0.0** | **0.0** | **0.0** |
| **211** | **ប្រាក់ខែ** | 7,731,219.9 | 5,663,266.6 | 73.25% | 567,032.3 | 545,595.4 | 684,204.5 | 542,299.6 | 613,089.5 | 692,869.6 | 712,086.8 | 654,314.4 | 651,774.3 | 0.0 | 0.0 | 0.0 |
| **22** | **ទំនិញ និងសេវាកម្ម** | **3,156,676.8** | **1,353,177.5** | **42.87%** | **31,086.1** | **76,603.5** | **84,867.3** | **123,585.7** | **188,249.0** | **163,603.0** | **227,878.3** | **261,863.9** | **195,440.6** | **0.0** | **0.0** | **0.0** |
| **24** | **ការប្រាក់** | **525,089.0** | **327,057.5** | **62.29%** | **62,608.2** | **50,120.9** | **38,398.7** | **9,578.1** | **7,152.3** | **1,825.1** | **69,094.4** | **65,961.8** | **22,318.0** | **0.0** | **0.0** | **0.0** |
| **241** | **បំណុលក្រៅប្រទេស** | 525,089.0 | 326,889.8 | 62.25% | 62,608.2 | 50,120.9 | 38,398.7 | 9,578.1 | 6,984.6 | 1,825.1 | 69,094.4 | 65,961.8 | 22,318.0 | 0.0 | 0.0 | 0.0 |
| **25** | **ការឧបត្ថម្ភធន** | **11,000.0** | **…** | **…** | **0.0** | **0.0** | **0.0** | **0.0** | **0.0** | **0.0** | **0.0** | **0.0** | **0.0** | **0.0** | **0.0** | **0.0** |
| **251** | **សហគ្រាសសាធារណៈ** | 11,000.0 | … | … | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| **26** | **អំណោយ** | **1,296,571.8** | **1,158,605.0** | **89.36%** | **206,840.8** | **7,515.2** | **136,246.2** | **210,623.3** | **93,397.7** | **187,391.8** | **239,283.7** | **36,167.8** | **41,138.5** | **0.0** | **0.0** | **0.0** |
| **262** | **អង្គការអន្តរជាតិ** | 166,837.2 | 50,099.4 | 30.03% | 124.8 | 3,383.4 | 6,276.2 | 5,244.9 | 14,149.0 | 4,433.2 | 5,824.9 | 5,998.1 | 4,664.9 | 0.0 | 0.0 | 0.0 |
| 2621 | ចរន្ត | 166,837.2 | 50,099.4 | 30.03% | 124.8 | 3,383.4 | 6,276.2 | 5,244.9 | 14,149.0 | 4,433.2 | 5,824.9 | 5,998.1 | 4,664.9 | 0.0 | 0.0 | 0.0 |
| **263** | **រដ្ឋាភិបាលដទៃទៀត (រដ្ឋបាលថ្នាក់ក្រោមជាតិ,...)** | 1,129,734.6 | 1,108,505.6 | 98.12% | 206,716.0 | 4,131.8 | 129,970.0 | 205,378.4 | 79,248.7 | 182,958.5 | 233,458.9 | 30,169.7 | 36,473.6 | 0.0 | 0.0 | 0.0 |
| 2631 | ចរន្ត | 1,129,734.6 | 1,108,505.6 | 98.12% | 206,716.0 | 4,131.8 | 129,970.0 | 205,378.4 | 79,248.7 | 182,958.5 | 233,458.9 | 30,169.7 | 36,473.6 | 0.0 | 0.0 | 0.0 |
| **27** | **ឧបត្ថម្ភសង្គមកិច្ច** | **1,596,371.5** | **1,212,335.4** | **75.94%** | **82,249.1** | **77,026.3** | **166,507.3** | **54,579.0** | **244,548.2** | **175,178.8** | **34,452.1** | **186,513.8** | **191,281.0** | **0.0** | **0.0** | **0.0** |
| **271** | **អត្ថប្រយោជន៍សន្តិសុខសង្គម** | 868,871.0 | 655,994.2 | 75.50% | 66,586.2 | 66,176.4 | 105,664.9 | 37,037.3 | 71,714.3 | 148,988.7 | 0.0 | 81,439.0 | 78,387.5 | 0.0 | 0.0 | 0.0 |
| **272** | **អត្ថប្រយោជន៍ជំនួយសង្គម** | 511,101.9 | 388,316.4 | 75.98% | 934.7 | 756.3 | 49,330.6 | 3,854.5 | 163,279.2 | 4,065.4 | 12,860.8 | 62,390.4 | 90,844.5 | 0.0 | 0.0 | 0.0 |
| **273** | **អត្ថប្រយោជន៍សង្គមសម្រាប់មន្ត្រីរាជការ** | 216,398.6 | 168,024.9 | 77.65% | 14,728.2 | 10,093.6 | 11,511.7 | 13,687.3 | 9,554.7 | 22,124.7 | 21,591.2 | 42,684.4 | 22,049.1 | 0.0 | 0.0 | 0.0 |
| **28** | **ចំណាយផ្សេងៗ** | **1,087,681.8** | **691,799.9** | **63.60%** | **5,372.8** | **31,368.1** | **139,851.2** | **40,558.8** | **48,369.0** | **117,973.8** | **81,281.4** | **42,428.1** | **184,596.6** | **0.0** | **0.0** | **0.0** |
| **282** | **ការផ្ទេរផ្សេងៗដែលមិនបានបែងចែក** | 1,087,681.8 | 691,205.4 | 63.55% | 5,372.8 | 31,190.2 | 139,628.1 | 40,558.8 | 48,369.0 | 117,804.2 | 81,277.5 | 42,408.2 | 184,596.6 | 0.0 | 0.0 | 0.0 |
| 2821 | ចរន្ត | 1,087,681.8 | 691,205.4 | 63.55% | 5,372.8 | 31,190.2 | 139,628.1 | 40,558.8 | 48,369.0 | 117,804.2 | 81,277.5 | 42,408.2 | 184,596.6 | 0.0 | 0.0 | 0.0 |
| **283** | **បុព្វលាភធានារ៉ាប់រង, និងផ្សេងៗ** | 1,756.2 | 594.4 | 33.85% | 0.0 | 177.8 | 223.1 | 0.0 | 0.0 | 169.7 | 3.9 | 20.0 | 0.0 | 0.0 | 0.0 | 0.0 |
| 2831 | បុព្វលាភធានារ៉ាប់រងចរន្ត | 1,756.2 | 594.4 | 33.85% | 0.0 | 177.8 | 223.1 | 0.0 | 0.0 | 169.7 | 3.9 | 20.0 | 0.0 | 0.0 | 0.0 | 0.0 |
| 28311 | បុព្វលាភធានារ៉ាប់រង | 1,756.2 | 594.4 | 33.85% | 0.0 | 177.8 | 223.1 | 0.0 | 0.0 | 169.7 | 3.9 | 20.0 | 0.0 | 0.0 | 0.0 | 0.0 |

# ២.៤.តារាងស្ថិតិបម្រែបម្រួលទ្រព្យសកម្ម/បំណុល

ឯកតា÷ លានរៀល

| | | ច្បាប់ឆ្នាំ ២០១៩ | អនុវត្តន៍ ២០១៩ | អនុ/ច្ប ២០១៩ | ប្រចាំខែ មករា | ប្រចាំខែ កុម្ភៈ | ប្រចាំខែ មីនា | ប្រចាំខែ មេសា | ប្រចាំខែ ឧសភា | ប្រចាំខែ មិថុនា | ប្រចាំខែ កក្កដា | ប្រចាំខែ សីហា | ប្រចាំខែ កញ្ញា | ប្រចាំខែ តុលា | ប្រចាំខែ វិច្ឆិកា | ប្រចាំខែ ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | វិធីសាស្ត្រគណនេយ្យ | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash |
| **3** | **បម្រែបម្រួលតម្លៃសុទ្ធនៃទ្រព្យកម្ម** | **4,713,061.6** | **7,927,457.0** | **168.20%** | **634,422.2** | **674,412.9** | **991,940.4** | **1,366,171.1** | **826,950.5** | **818,970.3** | **778,745.7** | **972,823.9** | **863,020.1** | **0.0** | **0.0** | **0.0** |
| **31** | **ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុសុទ្ធ** | **8,384,277.6** | **3,951,523.6** | **47.13%** | **268,327.0** | **285,839.1** | **608,778.5** | **441,431.8** | **396,412.6** | **562,088.0** | **696,557.5** | **436,668.9** | **255,420.3** | **0.0** | **0.0** | **0.0** |
| **311** | **អចលនទ្រព្យ** | 8,384,277.6 | 3,936,229.9 | 46.95% | 268,327.0 | 285,839.1 | 608,778.5 | 436,335.6 | 396,412.6 | 562,088.0 | 696,557.5 | 426,471.4 | 255,420.3 | 0.0 | 0.0 | 0.0 |
| **311A** | ***ការទិញ÷ អចលនទ្រព្យ*** | 8,384,286.6 | 3,950,772.9 | 47.12% | 268,327.0 | 285,839.1 | 608,778.5 | 436,335.6 | 407,362.8 | 562,088.0 | 700,150.3 | 426,471.4 | 255,420.3 | 0.0 | 0.0 | 0.0 |
| **311B** | ***ការលក់÷ អចលនទ្រព្យ*** | 9.0 | 14,543.0 | 161588.52% | 0.0 | 0.0 | 0.0 | 0.0 | 10,950.2 | 0.0 | 3,592.8 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| 3111 | អាគារ និងសំណង់ផ្សេងៗ | 7,672,380.0 | 3,693,518.4 | 48.14% | 261,742.1 | 190,692.1 | 594,195.8 | 424,048.1 | 382,403.7 | 537,958.4 | 671,089.1 | 399,660.2 | 231,729.0 | 0.0 | 0.0 | 0.0 |
| 3111A | *ការទិញ÷ អាគារ និងសំណង់ផ្សេងៗ* | 7,672,383.0 | 3,708,061.4 | 48.33% | 261,742.1 | 190,692.1 | 594,195.8 | 424,048.1 | 393,353.8 | 537,958.4 | 674,681.8 | 399,660.2 | 231,729.0 | 0.0 | 0.0 | 0.0 |
| 3111B | *ការលក់÷ អាគារ និងសំណង់ផ្សេងៗ* | 3.0 | 14,543.0 | 484765.55% | 0.0 | 0.0 | 0.0 | 0.0 | 10,950.2 | 0.0 | 3,592.8 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| 3112 | ម៉ាស៊ីន និងសម្ភារបរិក្ខា | 711,903.6 | 242,711.5 | 34.09% | 6,584.9 | 95,147.1 | 14,582.6 | 12,287.5 | 14,008.9 | 24,129.6 | 25,468.4 | 26,811.2 | 23,691.3 | 0.0 | 0.0 | 0.0 |
| 3112A | *ការទិញ÷ ម៉ាស៊ីន និងសម្ភារបរិក្ខា* | 711,903.6 | 242,711.5 | 34.09% | 6,584.9 | 95,147.1 | 14,582.6 | 12,287.5 | 14,008.9 | 24,129.6 | 25,468.4 | 26,811.2 | 23,691.3 | 0.0 | 0.0 | 0.0 |
| 3113 | អចលនទ្រព្យផ្សេងៗ | -6.0 | … | … | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| 3113B | *ការលក់÷ អចលនទ្រព្យផ្សេងៗ* | 6.0 | … | … | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| **32** | **ទ្រព្យសកម្មហិរញ្ញវត្ថុសុទ្ធ** | **-193,149.0** | **5,298,915.0** | **…** | **517,480.6** | **385,388.0** | **621,555.7** | **1,099,412.6** | **576,976.6** | **560,340.8** | **410,163.1** | **527,938.2** | **599,659.3** | **0.0** | **0.0** | **0.0** |
| 3202 | រូបិយប័ណ្ណ និងប្រាក់បញ្ញើ | 0.0 | 5,417,665.1 | … | 517,480.6 | 388,714.8 | 648,888.8 | 1,108,291.5 | 588,051.8 | 586,303.6 | 438,245.0 | 533,634.8 | 608,054.3 | 0.0 | 0.0 | 0.0 |
| **321** | **ក្នុងស្រុក** | -193,149.0 | 5,298,915.0 | … | 517,480.6 | 385,388.0 | 621,555.7 | 1,099,412.6 | 576,976.6 | 560,340.8 | 410,163.1 | 527,938.2 | 599,659.3 | 0.0 | 0.0 | 0.0 |
| 3212 | រូបិយប័ណ្ណ និងប្រាក់បញ្ញើ | 0.0 | 5,417,665.1 | … | 517,480.6 | 388,714.8 | 648,888.8 | 1,108,291.5 | 588,051.8 | 586,303.6 | 438,245.0 | 533,634.8 | 608,054.3 | 0.0 | 0.0 | 0.0 |
| **33** | **បំណុលសុទ្ធ** | **3,478,067.0** | **1,322,981.5** | **38.04%** | **151,385.4** | **-3,185.7** | **238,393.8** | **174,673.2** | **146,438.7** | **303,458.6** | **327,974.9** | **-8,216.8** | **-7,940.5** | **0.0** | **0.0** | **0.0** |
| 3304 | កម្ចី | 3,478,067.0 | 1,322,981.5 | 38.04% | 151,385.4 | -3,185.7 | 238,393.8 | 174,673.2 | 146,438.7 | 303,458.6 | 327,974.9 | -8,216.8 | -7,940.5 | 0.0 | 0.0 | 0.0 |
| **332** | **ក្រៅស្រុក** | 3,478,067.0 | 1,322,981.5 | 38.04% | 151,385.4 | -3,185.7 | 238,393.8 | 174,673.2 | 146,438.7 | 303,458.6 | 327,974.9 | -8,216.8 | -7,940.5 | 0.0 | 0.0 | 0.0 |
| 3324 | កម្ចី | 3,478,067.0 | 1,322,981.5 | 38.04% | 151,385.4 | -3,185.7 | 238,393.8 | 174,673.2 | 146,438.7 | 303,458.6 | 327,974.9 | -8,216.8 | -7,940.5 | 0.0 | 0.0 | 0.0 |

# ៣. ក្រាហ្វិក


ក្រាហ្វិកទី ១៖ សូចនាករសំខាន់ៗនៃប្រតិបត្តិការរដ្ឋាភិបាល
ឯកតា៖ គិតជាប៊ីលានរៀល
3,000
2,000
1,000
0
-1,000
-2,000
-3,000
មករា
មិនា
ឧសភា
កក្កដា
កញ្ញា
វិច្ឆិកា
ចំណូល{២០១៩}
ចំណាយ{២០១៩}
ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុសុទ្ធ{២០១៩}
ទ្រព្យសកម្មហិរញ្ញវត្ថុសុទ្ធ{២០១៩}
បំណុលសុទ្ធ{២០១៩}


ក្រាហ្វិកទី ២៖ ចំណូល (ពន្ធ អំណោយ និងផ្សេងៗ)
ឯកតា៖ គិតជាប៊ីលានរៀល
3,500
3,000
2,500
2,000
1,500
1,000
500
0
មករា
មិនា
ឧសភា
កក្កដា
កញ្ញា
វិច្ឆិកា
ចំណូលពន្ធ ២០១៩
អំណោល ២០១៩
ចំណូលផ្សេងៗ ២០១៩
ចំណូលពន្ធ ២០១៨
ចំណូលអំណោយ ២០១៨
ចំណូលផ្សេងៗ ២០១៨


ក្រាហ្វិកទី ៣៖ ចំណូលពន្ធ
ឯកតា៖ គិតជាប៊ីលានរៀល
1,400
1,200
1,000
800
600
400
200
0
មករា
មិនា
ឧសភា
កក្កដា
កញ្ញា
វិច្ឆិកា
ពន្ធលើប្រាក់ចំណូលនិងប្រាក់ចំណេញ ២០១៩
ពន្ធលើទំនិញ និងសេវាប្រើប្រាស់ ២០១៩
ពន្ធលើពាណិជ្ជកម្មអន្តរជាតិ ២០១៩
ពន្ធលើប្រាក់ចំណូល និងប្រាក់ចំណេញ ២០១៨
ពន្ធលើទំនិញ និងទំនិញប្រើប្រាស់ ២០១៨
ពន្ធលើពាណិជ្ជកម្មអន្តរជាតិ ២០១៨


ក្រាហ្វិកទី ៤៖ ចំណាយសរុប
ឯកតា៖ គិតជាប៊ីលានរៀល
3,500
3,000
2,500
2,000
1,500
1,000
500
0
មករា
មិនា
ឧសភា
កក្កដា
កញ្ញា
វិច្ឆិកា
ចំណាយ ២០១៩
ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ ២០១៩
ចំណាយ ២០១៨
ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ ២០១៨

# ៣. ក្រាហ្វិក


ក្រាហ្វិកទី ៥៖ ចំណាយ
ឯកតា៖ ពាន់លានរៀល
3,000
2,500
2,000
1,500
1,000
500
0
មករា
មិនា
ឧសភា
កក្កដា
កញ្ញា
វិច្ឆិកា
ចំណាយបន្ទុកបុគ្គលិក ២០១៩
ចំណាយមិនមែនបន្ទុកបុគ្គលិក ២០១៩
ចំណាយបន្ទុកបុគ្គលិក ២០១៨
ចំណាយមិនមែនបន្ទុកបុគ្គលិក ២០១៨


ក្រាហ្វិកទី ៦៖ ប្រតិបត្តិការទ្រព្យសកម្ម និងបំណុល
ឯកតា៖ ពាន់លានរៀល
2,000
1,500
1,000
500
0
-500
-1,000
-1,500
មករា
មិនា
ឧសភា
កក្កដា
កញ្ញា
វិច្ឆិកា
ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុសុទ្ធ ២០១៩
ទ្រព្យសកម្មហិរញ្ញវត្ថុសុទ្ធ ២០១៩
បំណុលសុទ្ធ ២០១៩
ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុសុទ្ធ ២០១៨
ទ្រព្យសកម្មហិរញ្ញវត្ថុសុទ្ធ ២០១៨
បំណុលសុទ្ធ ២០១៨


ក្រាហ្វិកទី ៧៖ ទ្រព្យសកម្មហិរញ្ញវត្ថុ
ឯកតា៖ ពាន់លានរៀល
1,200
1,000
800
600
400
200
0
-200
-400
-600
-800
មករា
មិនា
ឧសភា
កក្កដា
កញ្ញា
វិច្ឆិកា
រូបិយប័ណ្ណ និងប្រាក់បញ្ញើ ២០១៩
មិនមែនរូបិយប័ណ្ណ និងប្រាក់បញ្ញើ ២០១៩
រូបិយប័ណ្ណ និងប្រាក់បញ្ញើ ២០១៨
មិនមែនរូបិយប័ណ្ណ និងប្រាក់បញ្ញើ ២០១៨


ក្រាហ្វិកទី ៨៖ បំណុល
ឯកតា៖ ពាន់លានរៀល
400
350
300
250
200
150
100
50
0
-50
មករា
មិនា
ឧសភា
កក្កដា
កញ្ញា
វិច្ឆិកា
កម្ចី ២០១៩
មិនមែនកម្ចី ២០១៩
កម្ចី ២០១៨
មិនមែនកម្ចី ២០១៧

## ៤.ឧបសម្ព័ន្ធស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាលថ្នាក់ក្រោមជាតិ

ឯកតា÷ លានរៀល

| | | អនុវត្តន៍ ២០១៥ | អនុវត្តន៍ ២០១៦ | អនុវត្តន៍ ២០១៧ | អនុវត្តន៍ ឆ្នាំ២០១៨ | ច្បាប់ ២០១៩ | អនុវត្តន៍ ឆ្នាំ២០១៩ ឆមាស |
|---|---|---|---|---|---|---|---|
| | វិធីសាស្ត្រគណនយ្យ | Non Cash | Non Cash | Non Cash | Non Cash | Non Cash | Non Cash |
| **1** | **ចំណូល** | **1,449,977.4** | **1,444,774.2** | **1,796,172.6** | **2,848,913.3** | **2,096,477.9** | **1,393,830.9** |
| 11 | ពន្ធ | 761,372.3 | 755,258.1 | 1,009,595.3 | 1,547,749.0 | 1,351,615.7 | 738,866.7 |
| 12 | ការចូលរួមពីសង្គម | 0.0 | 0.0 | 0.0 | 0.0 | -1.0 | 0.0 |
| 13 | អំណោយ | 634,297.1 | 635,351.4 | 744,479.7 | 1,249,994.6 | 687,233.4 | 636,736.4 |
| 14 | ចំណូលផ្សេងៗ | 54,308.0 | 54,164.7 | 42,097.6 | 51,169.6 | 57,626.8 | 18,227.9 |
| **2** | **ចំណាយ** | **974,628.8** | **1,078,847.2** | **1,279,522.0** | **1,558,959.9** | **1,166,074.1** | **606,020.9** |
| 21 | បន្ទុកបុគ្គលិក | 225,075.1 | 308,999.5 | 343,718.4 | 402,780.3 | 470,938.1 | 216,692.2 |
| 22 | ទំនិញ និងសេវាកម្ម | 684,972.7 | 696,590.9 | 843,084.7 | 1,016,362.1 | 626,652.7 | 345,568.0 |
| 23 | ការប្រើប្រាស់ទុនអចល័ត | 0.0 | 0.0 | 0.0 | 0.0 | -1.0 | 0.0 |
| 24 | ការប្រាក់ | 0.0 | 0.0 | 0.0 | 0.0 | -1.0 | 0.0 |
| 25 | ឧបត្ថម្ភកធន | 0.0 | 0.0 | 0.0 | 0.0 | -1.0 | 0.0 |
| 26 | អំណោយ | 42.1 | 42.9 | 37.4 | 9.8 | 38.0 | 2.9 |
| 27 | ឧបត្ថម្ភសង្គមកិច្ច | 9,708.6 | 11,504.4 | 16,358.0 | 16,007.5 | 14,095.3 | 5,043.4 |
| 28 | ចំណាយផ្សេងៗ | 54,830.4 | 61,709.5 | 76,323.4 | 123,800.1 | 54,346.1 | 38,714.4 |
| ***GOB*** | *តុល្យភាពប្រតិបត្តិការដុល* | **475,348.6** | **365,927.1** | **516,650.6** | **1,289,953.4** | **930,402.8** | **787,810.1** |
| ***NOB*** | *តុល្យភាពប្រតិបត្តិការសុទ្ធ* | **475,348.6** | **365,927.1** | **516,650.6** | **1,289,953.4** | **930,402.8** | **787,810.1** |
| | **ប្រតិបត្តិការទ្រព្យមិនមែនហិរញ្ញវត្ថុ** | 0.0 | 0.0 | 0.0 | 0.0 | -1.0 | 0.0 |
| **31** | **ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុសុទ្ធ** | 313,219.4 | 294,622.4 | 304,720.5 | 507,180.4 | 490,299.1 | 111,851.3 |
| 311 | ទ្រព្យអចល័ត | 311,694.1 | 276,672.4 | 304,681.1 | 506,686.2 | 475,225.2 | 111,806.7 |
| 312 | បម្រែបម្រួលសន្និធិ | 0.0 | 0.0 | 0.0 | 0.0 | -1.0 | ... |
| 313 | វត្ថុមានតម្លៃ | 0.0 | 0.0 | 0.0 | 0.0 | -1.0 | ... |
| 314 | ទ្រព្យសកម្មគ្មានផលិតភាព | 1,525.3 | 17,950.0 | 39.4 | 494.2 | 15,072.9 | 44.7 |
| ***2M*** | *ចំណាយសរុប* | 1,287,848.2 | 1,373,469.6 | 1,584,242.6 | 2,066,140.3 | 1,656,373.3 | 717,872.2 |
| ***NLB*** | *សមតុល្យនៃការអោយខ្ចី/ប្រាក់កម្ចី* | **162,129.2** | **71,304.7** | **211,930.1** | **782,773.0** | **440,102.6** | **675,958.7** |
| | **ប្រតិបត្តិការទ្រព្យហិរញ្ញវត្ថុ និង បំណុល (ហិរញ្ញប្បទាន)** | 0.0 | 0.0 | 0.0 | 0.0 | -1.0 | 0.0 |
| **32** | **ទ្រព្យហិរញ្ញវត្ថុសុទ្ធ** | 271,748.2 | 52,119.5 | 333,478.0 | 873,100.9 | -1.0 | 393,895.3 |
| 321 | ក្នុងប្រទេស | 271,748.2 | 52,119.5 | 333,478.0 | 873,100.9 | -1.0 | 393,895.3 |
| 322 | ក្រៅប្រទេស | 0.0 | 0.0 | 0.0 | 0.0 | -1.0 | ... |
| **33** | **បំណុលសុទ្ធ** | 109,619.0 | -19,183.6 | 121,548.0 | 90,327.9 | -9,181.2 | -282,063.4 |
| 331 | ក្នុងប្រទេស | 109,619.0 | -19,183.6 | 121,548.0 | 90,327.9 | -9,181.2 | -282,063.4 |
| 332 | ក្រៅប្រទេស | 0.0 | 0.0 | 0.0 | 0.0 | -1.0 | 0.0 |

## តារាងស្ថិតិពីភាពខុសគ្នានៃស្ថិតិ TOFE និងស្ថិតិ GFS

ឯកតា៖ ប៊ីលានរៀល

| ស្ថិតិ TOFE (៩ខែ ដើមឆ្នាំ២០១៩) | | ស្ថិតិ GFS (៩ខែ ដើមឆ្នាំ២០១៩) | |
|---|---|---|---|
| **បរិយាយ** | **ការអនុវត្ត** | **ការអនុវត្ត** | **បរិយាយ** |
| I. ចំណូលក្នុងប្រទេស | 17,774 | 18,348 | ចំណូល |
| ១. ចំណូលចរន្ត | 17,653 | 15,386 | ពន្ធ |
| ក. ចំណូលពន្ធ | 15,573 | 15,386 | ពន្ធ |
| ការផាកពិន័យនិងទោសប្បញ្ញត្តិសារពើពន្ធ | (81) | | |
| ផលនៃការលក់ផ្ទេរគយ | (0) | | |
| ពិន័យផ្សេងៗលើការនាំចូល | (10) | | |
| ពិន័យផ្សេងៗពីការនាំចេញ | (1) | | |
| ការបង្វិលសងវិញនូវពន្ធនិងអាករផ្សេងៗ | (96) | | |
| | 15,386 | 15,386 | |
| ខ. ចំណូលមិនមែនពន្ធ | 2,080 | 2,135 | ចំណូលផ្សេងៗ |
| ផលនៃឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ | (15) | - | |
| ផលហិរញ្ញវត្ថុផ្សេងទៀត | (22) | - | |
| ការផាកពិន័យនិងទោសប្បញ្ញត្តិសារពើពន្ធ | 0 | (81) | |
| ផលនៃការលក់ផ្ទេរគយ | 0 | (0) | |
| ពិន័យផ្សេងៗលើការនាំចូល | 0 | (10) | |
| ពិន័យផ្សេងៗពីការនាំចេញ | 0 | (1) | |
| | 2,043 | 2,043 | |
| ២. ចំណូលមូលធន | 121 | - | |
| ការឲ្យខ្ចី(ការសងវិញនូវមូលធន) | (121) | - | |
| II. ចំណាយសរុប | 14,507 | 14,358 | ចំណាយសរុប (២+ ៣១) |
| ១. ចំណាយចរន្ត | 10,736 | 10,406 | ចំណាយ |
| ក. ចំណាយបៀវត្ស | 5,808 | 5,663 | បន្ទុកបុគ្គលិក |
| ប្រាក់វិភាជន៍សង្គមសម្រាប់មន្ត្រីរាជការ និងបុគ្គលិកផ្សេងៗ | (86) | - | |
| ប្រាក់វិភាជន៍សង្គមសម្រាប់គ្រួសារមន្ត្រីរាជការ | (67) | - | |
| បន្ទុកផ្សេងៗទៀត | (15) | - | |
| សោហ៊ុយបេសកកម្ម | - | (32) | |
| សោហ៊ុយបេសកកម្ម | - | (14) | |
| ផលហិរញ្ញវត្ថុផ្សេងទៀត | 0 | 22 | |
| | 5,640 | 5,640 | |
| ខ. ចំណាយមិនមែនបៀវត្ស | 4,928 | - | |
| ការទិញ | 809 | 1,353 | ទំនិញ និងសេវាកម្ម |
| សេវាកម្ម | 670 | - | |
| សម្ភារនិងបរិក្ខារបច្ចេកទេសមិនមែនព័ត៌មានវិទ្យា | (35) | - | |
| សង្ហារឹម | (32) | - | |
| សម្ភារនិងបរិក្ខារបច្ចេកទេសព័ត៌មានវិទ្យា | (145) | - | |
| សោហ៊ុយធានារ៉ាប់រង | (1) | - | |
| សោហ៊ុយបេសកកម្ម | (32) | - | |
| សោហ៊ុយបេសកកម្ម | (14) | - | |
| ការចូលរួមក្នុងការអនុវត្តគម្រោង | - | (132) | |

| ស្ថិតិ TOFE (៩ខែ ដើមឆ្នាំ២០១៩) | | ស្ថិតិ GFS (៩ខែ ដើមឆ្នាំ២០១៩) | |
|---|---|---|---|
| **បរិយាយ** | **ការអនុវត្ត** | **ការអនុវត្ត** | **បរិយាយ** |
| | 1,221 | 1,221 | |
| បន្ទុកហិរញ្ញវត្ថុ | 376 | 327 | ការប្រាក់ |
| បន្ទុកហិរញ្ញវត្ថុផ្សេងៗទៀត | (49) | - | |
| | 327 | 327 | |
| អត្ថប្រយោជន៍សង្គម | 1,356 | 1,212 | ឧបត្ថម្ភសង្គមកិច្ច |
| ជួយជនរងគ្រោះដោយគ្រោះធម្មជាតិ | (13) | - | |
| អាហារូបករណ៍សម្រាប់ការសិក្សា-ស្រាវជ្រាវក្នុងប្រទេស | (37) | - | |
| អាហារូបករណ៍សម្រាប់ការសិក្សា-ស្រាវជ្រាវក្រៅប្រទេស | (1) | - | |
| ជំនួយសង្គមផ្សេងៗទៀត | (168) | - | |
| ឧបត្ថម្ភដល់អង្គភាពដែលមានលក្ខណៈសង្គម និងវប្បធម៌ | (76) | - | |
| ចំណាយអន្តរាគមន៍ផ្នែកសង្គមកិច្ចនិងវប្បធម៌ | (4) | - | |
| អត្ថប្រយោជន៍សង្គមផ្សេងទៀត | (11) | - | |
| ប្រាក់វិភាជន៍សង្គមសម្រាប់មន្ត្រីរាជការ និងបុគ្គលិកផ្សេងៗ | - | (86) | |
| ប្រាក់វិភាជន៍សង្គមសម្រាប់គ្រួសារមន្ត្រីរាជការ | - | (67) | |
| បន្ទុកផ្សេងៗទៀត | - | (15) | |
| | 1,044 | 1,044 | |
| ឧបត្ថម្ភធន | 1,290 | 1,159 | អំណោយ |
| ការចូលរួមក្នុងការអនុវត្តគម្រោង | (132) | - | |
| ឧបត្ថម្ភធនផ្សេងៗ | (0) | - | |
| | 1,159 | 1,159 | |
| ចំណាយមិនមែនបៀវត្សផ្សេងៗ | 427 | 692 | ចំណាយផ្សេងៗ |
| ការបង្វិលសងវិញនូវពន្ធនិងអាករផ្សេងៗ | (96) | - | |
| សោហ៊ុយធានារ៉ាប់រង | - | (1) | |
| បន្ទុកហិរញ្ញវត្ថុផ្សេងៗទៀត | - | (49) | |
| ជួយជនរងគ្រោះដោយគ្រោះធម្មជាតិ | - | (13) | |
| អាហារូបករណ៍សម្រាប់ការសិក្សា-ស្រាវជ្រាវក្នុងប្រទេស | - | (37) | |
| អាហារូបករណ៍សម្រាប់ការសិក្សា-ស្រាវជ្រាវក្រៅប្រទេស | - | (1) | |
| ជំនួយសង្គមផ្សេងៗទៀត | - | (168) | |
| ឧបត្ថម្ភដល់អង្គភាពដែលមានលក្ខណៈសង្គម និងវប្បធម៌ | - | (76) | |
| ចំណាយអន្តរាគមន៍ផ្នែកសង្គមកិច្ចនិងវប្បធម៌ | - | (4) | |
| អត្ថប្រយោជន៍សង្គមផ្សេងទៀត | - | (11) | |
| ឧបត្ថម្ភធនផ្សេងៗ | - | (0) | |
| | 331 | 331 | |
| ២. ចំណាយមូលធន | 3,771 | 3,952 | ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុសុទ្ធ |
| Tangible fixed assets and land | - | - | |
| ផលនៃឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ | - | 15 | |
| សម្ភារនិងបរិក្ខារបច្ចេកទេសមិនមែនព័ត៌មានវិទ្យា | - | (35) | |
| សង្ហារឹម | - | (32) | |
| សម្ភារនិងបរិក្ខារបច្ចេកទេសព័ត៌មានវិទ្យា | - | (145) | |
| | 3,754 | 3,754 | |
| តុល្យភាពសរុប ឱនភាព/អតិរេក (I-II) | 3,267 | 3,990 | សមតុល្យនៃការអោយខ្ចី/ប្រាក់កម្ចី |

| ស្ថិតិ TOFE (៩ខែ ដើមឆ្នាំ២០១៩) | | ស្ថិតិ GFS (៩ខែ ដើមឆ្នាំ២០១៩) | |
|---|---|---|---|
| **បរិយាយ** | **ការអនុវត្ត** | **ការអនុវត្ត** | **បរិយាយ** |
| អំណោយ | 799 | - | |
| ២.ចំណូលមូលធន | (121) | - | |
| | 3,990 | 3,990 | |
| III. ហិរញ្ញប្បទាន | (3,267) | - | |
| ហិរញ្ញប្បទានពីក្រៅប្រទេស | 2,151 | 1,323 | បំណុលសុទ្ធ |
| អំណោយ | (799) | - | |
| | 1,323 | 1,323 | |

## ៥.សេចក្តីសង្ខេបស្តីអំពី "ក្របខ័ណ្ឌប្រព័ន្ធស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល"

## អនុលោមទៅតាម Government Finance Statistics (GFSM2014)

1. **របាយការណ៍ប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋាភិបាល**

**1.1.របាយការណ៍ប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋាភិបាល** ជារបាយការណ៍មួយដែលបង្ហាញយ៉ាងលម្អិតតាមរយៈប្រតិបត្តិការសំខាន់ៗ ដូចជា÷ ចំណូល, ចំណាយ, វិនិយោគសុទ្ធលើទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ, វិនិយោគសុទ្ធលើទ្រព្យសកម្មហិរញ្ញវត្ថុ, និងបំណុលសុទ្ធ។ ផ្អែកលើក្របខ័ណ្ឌស្តង់ដារស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាលនេះ **ចំណូល** គឺជាប្រតិបត្តិការ (transaction) ដែលធ្វើឱ្យតម្លៃសុទ្ធនៃទ្រព្យសកម្ម (net worth) កើនឡើង។ រីឯ**ចំណាយ** គឺជាប្រតិបត្តិការ (transactions) ដែលធ្វើឲ្យតម្លៃសុទ្ធនៃទ្រព្យសកម្មថយចុះ។ **ការវិនិយោគសុទ្ធលើទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ**គឺជាលទ្ធផលនៃអចលនទ្រព្យ (fixed assets) បូកសន្និធិសុទ្ធ, ទ្រព្យមានតម្លៃសុទ្ធ និងទ្រព្យគ្មានផលិតភាពសុទ្ធ (non-produce assets) ។

1.2. នៅក្នុងរបាយការណ៍ប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋាភិបាលមានតុល្យភាពចំនួន ០២ ដែលជាធាតុដ៏សំខាន់ក្នុងកិច្ចការវិភាគ។ តុល្យភាពទី១ គឺជាផលសងនៃចំណូល និងចំណាយ ដែលហៅថា **តុល្យភាពប្រតិបត្តិការសុទ្ធ** និងតុល្យភាពទី២ គឺជាផលសងនៃតុល្យភាពប្រតិបត្តិការសុទ្ធ និងការវិនិយោគលើទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុសុទ្ធ ដែលហៅថា **តុល្យភាពការឲ្យខ្ចី/ប្រាក់កម្ចីសុទ្ធ**។ តុល្យភាពទី២នេះ ក៏អាចបង្ហាញតាមរយៈផលសងនៃការវិនិយោគសុទ្ធលើទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលសុទ្ធ។

**1.3.តុល្យភាពប្រតិបត្តិការសុទ្ធ** ទិន្នន័យតុល្យភាពនេះអាចយកទៅប្រៀបធៀបជាមួយគណនីជាតិតាមរយៈការបូកបញ្ចូលគ្នានៃការសន្សំ និងមូលនិធិផ្ទេរដែលត្រូវទទួល។ **តុល្យភាពប្រតិបត្តិការសុទ្ធ**នៅទីនេះមិនបានរាប់បញ្ចូលចំណេញ ឬខាតដែលកើតចេញពី ការប្រែប្រួលថ្លៃ (change in price level) និងការប្រែប្រួលជាបរិមាណ (other change in the volume)ទ្រព្យសកម្ម ឬបំណុលឡើយ។ គោលនយោបាយរបស់ រដ្ឋាភិបាលមានឥទ្ធិពលផ្ទាល់លើប្រតិបត្តិការដែលធ្វើឱ្យតម្លៃសុទ្ធនៃទ្រព្យប្រែប្រួលព្រោះតែរដ្ឋាភិបាលជាអ្នកគ្រប់គ្រងដោយផ្ទាល់លើសេចក្តីសម្រេចចិត្តចំពោះគ្រប់ប្រតិបត្តិការទាំងអស់។ ចំណេញ ឬខាតចេញពីការប្រែប្រួលតម្លៃសុទ្ធនៃទ្រព្យសកម្ម ឬបំណុល (ប្រែប្រួលថ្លៃទីផ្សារ) និងការប្រែប្រួលជាបរិមាណ (ដោយសារព្រឹត្តិការណ៍ណាមួយ) គឺមិនស្ថិតនៅក្រោមការគ្រប់គ្រងដោយផ្ទាល់របស់រដ្ឋាភិបាលឡើយ តែរដ្ឋាភិបាលអាចមានយន្តការ ឬគោលនយោបាយដើម្បីកាត់បន្ថយផលប៉ះពាល់ដែលកើតចេញពីការប្រែប្រួលខាងលើឲ្យស្ថិតក្នុងកម្រិតអប្បរមា។

1.4. **តុល្យភាពការឲ្យខ្ចី/ប្រាក់កម្ចីសុទ្ធ** ដែលបង្ហាញឲ្យឃើញពីការប្រើប្រាស់ (វិនិយោគ) ធនធានហិរញ្ញវត្ថុទៅវិស័យខាងក្រៅទាំងសេដ្ឋកិច្ចក្នុងប្រទេស ឬក្រៅប្រទេស (ការឲ្យខ្ចី) ឬបង្ហាញឲ្យឃើញពីការទាញយកអត្ថប្រយោជន៍ប្រភពហិរញ្ញប្បទាន

ពីវិស័យខាងក្រៅទាំងសេដ្ឋកិច្ចក្នុងប្រទេស ឬក្រៅប្រទេស (ប្រាក់កម្ចី)។ តុល្យភាពនេះជាសូចនាករមួយដែលបង្ហាញឱ្យឃើញពីឥទ្ធិពលនៃសកម្មភាពហិរញ្ញវត្ថុរបស់រដ្ឋាភិបាលទៅលើសេដ្ឋកិច្ចទាំងក្នុង និងក្រៅប្រទេស។

**1.5. តុល្យភាពប្រតិបត្តិការដុល÷** មានភាពខុសគ្នាពីតុល្យភាពប្រតិបត្តិការសុទ្ធនៅត្រង់ថាតុល្យភាពប្រតិបត្តិការដុលមិនបានរួមបញ្ចូលនូវចំណាយលើការប្រើប្រាស់ (រំលស់)ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុឡើយ។ ចំណាយលើការប្រើប្រាស់ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុមានភាពលំបាកក្នុងការវាយតម្លៃ។ ប្រសិនបើតុល្យភាពប្រតិបត្តិការដុលធំជាងតុល្យភាពប្រតិបត្តិ-ការសុទ្ធនេះមានន័យថាចំណាយលើការប្រើប្រាស់លើទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុត្រូវបានកត់ត្រា។

**1.6. ចំណាយសរុប** (expenditure) គឺជាលទ្ធផលដែលបានមកពីចំណាយ (expenses) និងវិនិយោគ (ការទិញ/ដោះដូរ)លើទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ។ ចំណាយសរុបនេះបានរួមបញ្ចូលទាំងចំណាយលើការប្រើប្រាស់ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុមានភាពសមស្របសម្រាប់ការប្រៀបធៀបជាមួយបណ្តាប្រទេសផ្សេងៗ បើទោះបីជាការវាយតម្លៃចំណាយរំលស់នៅមិនទាន់មានសង្គតិភាពនៅឡើយក៏ដោយ។

**1.7. ចំណូល** គឺជាប្រតិបត្តិការ (transaction) ដែលធ្វើឱ្យតម្លៃសុទ្ធនៃទ្រព្យកើនឡើង។ ធាតុសំខាន់ៗនៃចំណូលរួមមាន÷ ចំណូលពន្ធ (១១), ចំណូលពីការចូលរួមសង្គម (១២), ចំណូលពីអំណោយ (១៣), និងចំណូលផ្សេងៗ (១៤) ។ ចំណូលដែលបានមកពីការលក់ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុដែលប្រើប្រាស់រួច (ជម្រះបញ្ជី) មិនត្រូវបានទទួលស្គាល់ជាចំណូលឡើយ ពីព្រោះវាមិនបានធ្វើឱ្យមានការប្រែប្រួលតម្លៃសុទ្ធនៃទ្រព្យសកម្មនោះទេ។ អ្វីដែលប្រែប្រួលចេញពីប្រតិបត្តិការនេះគឺ ការប្រែប្រួលសមាសធាតុដែលមាននៅក្នុងតារាងតុល្យភាពតែប៉ុណ្ណោះ ពោលគឺទ្រព្យសកម្មមួយថយចុះ (ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ)ហើយ ទ្រព្យសកម្មផ្សេងកើនឡើង (សាច់ប្រាក់)។ ដូចគ្នាដែរសម្រាប់ប្រាក់កម្ចីដែលទទួលបាន ឬការសងបំណុលដែលគេជំពាក់ ក៏មិនត្រូវបានចាត់ទុកជាចំណូលដែរ។

**1.8. ចំណាយ** គឺជាប្រតិបត្តិការ (transaction)ដែលធ្វើឱ្យតម្លៃសុទ្ធនៃទ្រព្យថយចុះ។ ធាតុសំខាន់ៗនៃចំណាយ រួមមាន÷ ចំណាយប្រាក់បៀវត្ស និងលាភការ (២១), ចំណាយការប្រើប្រាស់ទំនិញ និងសេវាកម្ម (២២), ចំណាយលើការប្រាក់ (២៤) ,ចំណាយលើការឧបត្ថម្ភធន (២៥), ចំណាយលើអំណោយ (២៦) ចំណាយលើឧបត្ថម្ភសង្គមកិច្ច (២៧), និងចំណាយផ្សេងៗ(២៨)។ មិនត្រឹមតែប៉ុណ្ណោះ ចំណាយក៏ត្រូវបានធ្វើចំណាត់ថ្នាក់ ទៅតាមមុខងាររបស់រដ្ឋាភិបាលផងដែរ ដូចជា÷ ចំណាយលើសុខភាព ឬកិច្ចការពារសង្គមជាដើម។ ការទិញ ឬដោះដូរទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ មិនត្រូវបានចាត់ទុកជាចំណាយឡើយ ពីព្រោះវាមិនបានធ្វើឱ្យមានការប្រែប្រួលតម្លៃសុទ្ធនៃទ្រព្យឡើយ។ ការប្រែប្រួលកើតចេញពីប្រតិបត្តិការខាងលើនេះគឺ ការប្រែប្រួលសមាសធាតុដែលមាននៅក្នុងតារាងតុល្យភាពតែប៉ុណ្ណោះ។ ដូចគ្នាដែរសម្រាប់ប្រាក់កម្ចីដែលបានសង ក៏មិនត្រូវបានចាត់ទុកជាចំណាយដែរ។

**1.9.** ផ្នែកទី៣នៃរបាយការណ៍ប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋាភិបាលនេះ គឺជា**ប្រតិបត្តិការហិរញ្ញវត្ថុ** ទាំងឡាយដែលធ្វើឱ្យមានបម្រែបម្រួលទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុល។ ប្រតិបត្តិការហិរញ្ញវត្ថុត្រូវបានធ្វើចំណាត់ថ្នាក់ដោយផ្អែកលើដៃគូ (counterpart) ដែលបានជាប់ពាក់ (ទាំងក្នុង និងក្រៅប្រទេស) ទាំងក្នុងទ្រព្យសកម្ម និងបំណុល។

**1.10.** បន្ថែមលើចំណាត់ថ្នាក់ខាងលើ ប្រតិបត្តិការទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលក៏ត្រូវបានធ្វើចំណាត់ថ្នាក់ដោយផ្អែកលើប្រភេទឧបករណ៍ហិរញ្ញវត្ថុដែលមានដូចជា÷ រូបិយវត្ថុ មាស និងអេសឌីអា, រូបិយប័ណ្ណ និងប្រាក់បញ្ញើ, មូលបត្របំណុល, កម្ចី, ដើមទុន និងមូលនិធិភាគហ៊ុន, ធានារ៉ាប់រង សោធន និងកញ្ចប់ធានារ៉ាប់រង, ដេរីវេទីវហិរញ្ញវត្ថុ និងភាគហ៊ុនបុគ្គលិក, គណនីត្រូវទទួល/ត្រូវសងផ្សេងៗ។ មិនត្រឹមតែប៉ុណ្ណោះប្រតិបត្តិការទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលក៏ត្រូវបានធ្វើចំណាត់ថ្នាក់ដោយផ្អែកលើវិស័យដែលជាដៃគូបដិភាគនៃឧបករណ៍ហិរញ្ញវត្ថុដូចជា÷ សាជីវកម្មហិរញ្ញវត្ថុ, សាជីវកម្មមិនមែនហិរញ្ញវត្ថុ, គេហកិច្ច (household) និងស្ថាប័នមិនស្វែងរកប្រាក់ចំណេញ។

**1.11.** មធ្យោបាយម្យ៉ាងទៀត នៃការធ្វើចំណាត់ថ្នាក់ប្រតិបត្តិការទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុល គឺដោយផ្អែកលើការកើនឡើងថ្មី ឬក៏ការជម្រះចេញ ដែលបម្រើឱ្យគោលដៅនយោបាយ ឬក៏ផ្អែកលើការគ្រប់គ្រងសន្ទនីភាព។ ភាពខុសគ្នានោះនៅត្រង់ថាវាមិនត្រូវបានរាប់បញ្ចូលក្នុងរបាយការណ៍ប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋាភិបាលទេ តែវាត្រូវប្រើសម្រាប់កំណត់តុល្យភាពសារពើពន្ធ។

**1.12.** គោលនយោបាយសាធារណៈដែលទាក់ទងទៅនឹងទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលអាចត្រូវបានលើកមកគិតគូរក្នុងហេតុផលផ្សេងៗ ដូចជាការជម្រុញឧស្សាហកម្មថ្មី, ជួយសង្គ្រោះសាជីវកម្មសាធារណៈ, ឬក៏ជួយអាជីកម្មណាមួយដើម្បីឱ្យមានភាពសម្បូរបែបក្នុងសេដ្ឋកិច្ច។ ប្រតិបត្តិការទាំងនេះអាចមានទម្រង់ផ្សេងៗគ្នាដូចជា÷ កម្ចី, មូលបត្រដើមទុន ឬមូលបត្របំណុលជាដើម។ ជាមួយគ្នានេះដែរ ប្រតិបត្តិការខាងលើក៏អាចមានផងដែរក្នុងទម្រង់ជាសម្បទាន។

**1.13.** ប្រតិបត្តិការទ្រព្យសកម្មហិរញ្ញវត្ថុផ្សេងៗទៀត គឺត្រូវបានសន្មត់ថាជាការគ្រប់គ្រងសន្ទនីភាពឬក៏គោលបំណងផ្សេង។ ដែលនេះបង្ហាញថាទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានគ្រប់គ្រងដោយបានទាញយកផលប្រយោជន៍ស្របតាមអត្រាទីផ្សារ ព្រមទាំងធានាបាននូវមូលនិធិគ្រប់គ្រាន់សម្រាប់ប្រតិបត្តិការប្រចាំថ្ងៃ ឬគ្រប់គ្រាន់ជាមួយតម្រូវការសង្គមនៅពេលខាងមុខដូចជាមូលនិធិពិសេសរបស់រដ្ឋាភិបាលជាដើម។